ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២១ លេខ៦៦ ត្រីមាសទី០៣ ឆ្នាំ២០២១

# រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារធាតុ

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

២៤-១១-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១១២១/៧៩៤ ស្តីពី ការកែសម្រួលមាត្រា២ថ្មីនៃព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៤១៣ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា២នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/ ៤០៣ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិ អភិវឌ្ឍន៍ដោយចីរភាព និងមាត្រា៥និងមាត្រា១០នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/ ៤០៣ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ៨១២៩

២៤-១១-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១១២១/៧៩៥ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **ផាក សាខរហ្វ** ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ រដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បំណាច់មុខងារ ៨១៣៤

២៦-១១-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១១២១/៧៩៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសសុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ជាកិច្ចបច្ឆាមរណៈ ចំពោះមហាឧបាសិកា **ស ស៊ន់** ដែលបានទទួលមរណភាព ៨១៣៥

២៦-១១-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១១២១/៧៩៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **យ៉ាង វីរៈយុទ្ធ (YANG, VIREAKYUTH)** ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ ៨១៣៦

២៦-១១-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១១២១/៧៩៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ស៊ូ យុនហ៊ុយ (XU, YUNHUI)** ជនជាតិចិន សញ្ជាតិចិន ៨១៣៧

២៦-១១-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១១២១/៧៩៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **វ៉ាង ចៀនវូ (WANG JIANWU)** ជនជាតិសាំងលូស៊ី សញ្ជាតិសាំងលូស៊ី ៨១៣៨

២៩-១១-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១១២១/៨០០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសសម្តេចព្រះមហាក្សត្រយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ ជាកិច្ចបច្ឆាមរណៈ ថ្វាយ សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ដែលបានយាងចូលព្រះទិវង្គត ៨១៣៩

៣០-១១-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១១២១/៨០១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសដល់មន្ត្រីពន្ធនាគារ នៃក្រសួងមហាផ្ទៃ ៧រូប ៨១៤០

៣០-១១-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១១២១/៨០២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ដល់មន្ត្រីរាជការនៃក្រសួងយុត្តិធម៌ ២៣រូប ៨១៤១


## II~រដ្ឋសភា


២៥-១១-២០២១ -សេចក្តីប្រកាសលេខ ០៩៥ រ.ស ស្តីពី ការសម្រេចអំពីសុពលភាពនៃអាណត្តិ របស់តំណាងរាស្ត្រ នីតិកាលទី៦ នៃរដ្ឋសភា ៨១៤៣


## III~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


១៥-១១-២០២១ -អនុក្រឹត្យលេខ ២២៨ អនក្រ.បក ស្តីពី ការបង្កើតតំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងកាដេរ ៨១៤៤

២៤-១១-២០២១ -អនុក្រឹត្យលេខ ២៣៥ អនក្រ.បក ស្តីពី ការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុង រាជធានីភ្នំពេញ ៨១៤៩

២៤-១១-២០២១ -អនុក្រឹត្យលេខ ២៣៦ អនក្រ.បក ស្តីពី ការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុង រាជធានីភ្នំពេញ ៨១៥១

២២-៩-២០២១ -អនុក្រឹត្យលេខ ៤៥៣ អនក្រ.តត ស្តីពី ការសម្រួលភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៨១៥៣

១១-១១-២០២១ -អនុក្រឹត្យលេខ ៥២៥ អនក្រ.តត ស្តីពី ការផ្ទេរ និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិ កម្ពុជា ៨១៥៥

១១-១១-២០២១ -អនុក្រឹត្យលេខ ៥២៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨១៥៦

១១-១១-២០២១ -អនុក្រឹត្យលេខ ៥២៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៨១៥៨

១១-១១-២០២១ -អនុក្រឹត្យលេខ ៥២៨ អនក្រ.តត ស្តីពី ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើប ការណ៍ហិរញ្ញវត្ថុកម្ពុជា អាណត្តិទី១ ៨១៦០

១១-១១-២០២១ -អនុក្រឹត្យលេខ ៥២៩ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៨១៦២


### ២~សេចក្តីសម្រេច


២-១២-២០២១ -សេចក្តីសម្រេចលេខ ១១៦ សសរ ស្តីពី ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីបង្ការនិង បង្ក្រាបការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធនិងការប្រើប្រាស់សេវាទូរគមនាគមន៍ឆ្លងដែនខុសច្បាប់ ៨១៦៣


### ៣~សារាចរណែនាំ


៣-១២-២០២១ -សារាចរណែនាំលេខ ០៦ សរណន ស្តីពី ការចូលរួមគោរពព្រះវិញ្ញាណក្ខន្ធព្រះសពសម្តេច ក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានក្រុម ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា អតីតនាយករដ្ឋមន្ត្រីទី១ និងជាអតីតប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ៨១៦៧

# IV~ការងារបណ្ដាក្រសួង

## ១~ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


| | | |
|---|---|---|
| ៣០-៦-២០២១ | -ប្រកាសលេខ ៣៦០ សហវ.ប្រក ស្ដីពី ការបង្កើតអង្គភាពអនុវត្តគម្រោង សម្រាប់សមាសភាគទី១ ស្ដីពីការលើកកម្ពស់ខ្សែច្រវ៉ាក់តម្លៃកសិកម្ម នៃគម្រោងប្រគួតប្រជែងខ្សែច្រវ៉ាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម | ៨១៦៨ |
| ៨-៧-២០២១ | -ប្រកាសលេខ ៣៦៩ សហវ.ប្រក ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៨១៧៣ |
| ១៧-៨-២០២១ | -ប្រកាសលេខ ៥០២ សហវ.ប្រក ស្ដីពី ការកែសម្រួលចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិសម្រាប់ក្រសួងចំនួនដប់ពីរ | ៨១៧៨ |
| ៣០-៨-២០២១ | -ប្រកាសលេខ ៥២៦ សហវ.ប្រក ស្ដីពី ការកំណត់ប្រភព និងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់នីយ័តករធានារ៉ាប់រងកម្ពុជា | ៨១៨០ |


## ២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍


| | | |
|---|---|---|
| ៣១-៣-២០២១ | -ប្រកាសលេខ ១២៩ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ី.អ.ស៊ី.ខេ អភិវឌ្ឍន៍កៅស៊ូ បង្កើតរោងចក្រ កែច្នៃជ័រកៅស៊ូ | ៨១៨៦ |
| ៣១-៣-២០២១ | -ប្រកាសលេខ ១៣០ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេធិច អ៊ិនធើណេសិនណល (ខេមបូឌា) អិលធីឌី បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ | ៨១៨៩ |
| ៣១-៣-២០២១ | -ប្រកាសលេខ ១៣១ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន បាយ៉ន ហ្គាមេន ហ្វាកធើរី បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ | ៨១៩២ |
| ៣១-៣-២០២១ | -ប្រកាសលេខ ១៣២ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន លី ប៉ាង ស៊ូ អិកសេសសឺរី (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតគ្រឿងបន្សំស្បែកជើង និងការស្បែកជើង | ៨១៩៥ |
| ៣១-៣-២០២១ | -ប្រកាសលេខ ១៣៣ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ុយ យ៉ាត អេ (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតកាបូបគ្រប់ប្រភេទ ថង់ប្លាស្ទិក អេប៉ុង ស្កុត និងកេសកាតុង | ៨១៩៨ |
| ៣១-៣-២០២១ | -ប្រកាសលេខ ១៣៤ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីន ជេលលី អ៊ិនដាសស្ទ្រី អេន ត្រេឌីង ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ និងកំណាត់ទ្រនាប់សម្លៀកបំពាក់ | ៨២០១ |
| ៣១-៣-២០២១ | -ប្រកាសលេខ ១៣៥ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សាន់រ៉ាយស៍ ឡៃថ៍ អេនធើប្រាយ ឯ.ក បង្កើតរោងចក្រ ផលិតខ្សែភ្លើង និងអំពូលភ្លើង | ៨២០៤ |

៣១-៣-២០២១ -ប្រកាសលេខ ១៣៦ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ាន់ធីជ រីជើរ ថេកស្ថាយ បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៨២០៧
៣១-៣-២០២១ -ប្រកាសលេខ ១៣៧ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សផ្លេនឌើរ អ៊ិនដាសស្ទ្រី បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៨២១០

## ៣~ទីស្តីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល

៣-១១-២០២០ -ប្រកាសលេខ ០៥០១ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០៥០១ រថ.អប្រក.លអ ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៨២១៣
៣-១១-២០២០ -ប្រកាសលេខ ០៥០២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០៥០២ រថ.អប្រក.លអ ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៨២១៧
៣-១១-២០២០ -ប្រកាសលេខ ០៥០៣ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០៥០៣ រថ.អប្រក.លអ ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៨២២១
៤-១១-២០២០ -ប្រកាសលេខ ០៥០៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការទីតាំង វេចខ្ចប់ឧស្ម័នអិល ភី ជី លេខ ០៥០៤ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៨២២៥
៤-១១-២០២០ -ប្រកាសលេខ ០៥០៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០៥០៦ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៨២២៩
៤-១១-២០២០ -ប្រកាសលេខ ០៥០៧ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ រួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០៥០៧ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៨២៣៣
៤-១១-២០២០ -ប្រកាសលេខ ០៥០៩ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០៥០៩ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៨២៣៧
៤-១១-២០២០ -ប្រកាសលេខ ០៥១៥ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០៥១៥ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៨២៤១
៤-១១-២០២០ -ប្រកាសលេខ ០៥១៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០៥១៦ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៨២៤៥
១២-១១-២០២០ -ប្រកាសលេខ ០៥២០ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ រួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០៥២០ រថ.អប្រក.លអ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៨២៤៩

# ព្រះរាជក្រឹត្យ
# ស្តីពី

នស/រកត/១១២១/៧៩៤

**ការកែសម្រួលមាត្រា២ថ្មីនៃព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៤១៣ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា២នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងមាត្រា៥និងមាត្រា១០នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៦ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជីវសុវត្ថិភាព
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៤១៣ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលមាត្រា២នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រាមួយ .-**

មាត្រា២ថ្មីនៃព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៤១៣ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលមាត្រា២នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងមាត្រា៥និងមាត្រា១០នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**មាត្រា២ .- ថ្មី(ពីរ)**

**ក.ជ.អ.ច.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | ប្រធានកិត្តិយស |
| - រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ប្រធាន |
| - រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី១រូប | អនុប្រធានទី១ |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន១រូប | អនុប្រធានទី២ |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍១រូប | សមាជិក |

- រដ្ឋលេខាធិការក្រសួងផែនការ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងព័ត៌មាន១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងយុត្តិធម៌១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសុខាភិបាល១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងទេសចរណ៍១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងកិច្ចការនារី១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ១រូប សមាជិក
- រដ្ឋលេខាធិការរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល១រូប សមាជិក
- អគ្គលេខាធិការឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ សមាជិក
- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
- អនុប្រធានប្រតិបត្តិលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សមាជិក
- អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ សមាជិក
- អគ្គលេខាធិការគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ សមាជិក
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត សមាជិក
- អគ្គលេខាធិការគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្រ ក្រសួងបរិស្ថាន សមាជិកអចិន្ត្រៃយ៍។

សមាសភាពជាក់ស្តែងរបស់**គ.ជ.អ.ច.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៥ .. ថ្មី**

**គ.ជ.អ.ច.** មានគណៈកម្មាធិការប្រតិបត្តិមួយ ដែលមានសមាសភាពដូចខាងក្រោម៖



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

- រដ្ឋមន្ត្រីក្រសួងបរិស្ថាន ប្រធាន
- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ១រូប អនុប្រធានទី១
- រដ្ឋលេខាធិការក្រសួងបរិស្ថាន១រូប អនុប្រធានទី២
- រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន១រូប សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្រ ក្រសួងបរិស្ថាន សមាជិកអចិន្ត្រៃយ៍។

សមាសភាពជាក់ស្តែងរបស់**អ.ជ.អ.ច.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា១០ ..ថ្មី**

**អ.ជ.អ.ច.** មានអគ្គនាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្រនៃក្រសួងបរិស្ថានជាលេខាធិការដ្ឋាន។

**មាត្រាពីរ ..**

មន្ត្រីរាជការនិងទ្រព្យសម្បត្តិនៃអគ្គលេខាធិការដ្ឋាន**អ.ជ.អ.ច.** ត្រូវបានផ្ទេរឱ្យស្ថិតក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។

**មាត្រាបី ..**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការតែងតាំងមន្ត្រីរាជការនិងការបង្កើតអង្គភាពនានាចំណុះអគ្គលេខាធិការដ្ឋាន**អ.ជ.អ.ច.** ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

**មាត្រាបួន ..**

អនុក្រឹត្យលេខ៥៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា៤ .-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ ព្រហ ៥រោច ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០២១

នស.រកត.១១២១.៥៦២

ន សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/១១២១/ ៧៩៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម / ០៦១៨ / ០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង និងផ្តល់ឋានៈឯកឧត្តម **ផាក សាខហ្វ** ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើរដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បំណាច់មុខងារ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ពរស.២១១១.៥១៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/១១២១/៧៩៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

នូវ

គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

**ជាកិច្ចបច្ឆាមរណៈ**

ចំពោះមហាឧបាសិកា **ស សិន់**
ដែលបានទទួលមរណភាព

ន.សីហមុនី

ពារស.២១១១.៩១៤

បានប្រទាប់ព្រះរាជលញ្ឆករហើយ

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០២១

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
លេខ: ...០១៤/២១...... រវ.ចច
រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២១
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឧត្តម **គង់ សំអុល**
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រឹត្យ

នស/រកត/១១២១/ ៧៩៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **យ៉ាង វីរៈយុទ្ធ** (YANG, VIREAKYUTH) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ កើតថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៩៩ នៅទីក្រុង Kaohsiung សាធារណរដ្ឋចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរស ២០១១.៨១៥

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២១*

បានថ្វាយជូនឡាយព្រះហស្តលេខាតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រី ប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/១១២១/ ៧៩៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ស៊ូ យុនហ៊ុយ** (XU, YUNHUI) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៧៨ នៅខេត្ត Fujian សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរ.ស. ២១១១.៥១៦

នរោត្តម សីហមុនី (ហត្ថលេខា)

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២១*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/១១២១/ [illegible]

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **វ៉ាង ចៀនវូ** (WANG JIANWU) ជនជាតិសាំងលូស៊ី សញ្ជាតិសាំងលូស៊ី កើតថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៨ នៅសាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២១*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/១១២១/៩០០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

នូវ

គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន**
ថ្នាក់ **មហាសេរីវឌ្ឍន៍**

**ជាកិច្ចបច្ឆាមរណៈ**

**ថ្វាយ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ**
**ដែលបានយាងចូលព្រះនិវង្គត**

**នរោត្តម សីហមុនី**

ពរស. ២១១១.៩១៤
**បានប្រទាប់ព្រះរាជលញ្ឆករហើយ**
ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០២១

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
លេខ: ០១៥/២១ រ.ចច
រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០២១
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ **គង់ សំអុល**
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រឹត្យ

នស/រកត/១១២១/៩០១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**នូវ**

គ្រឿងឥស្សរិយយស ដល់មន្ត្រីពន្ធនាគារនៃក្រសួងមហាផ្ទៃ ៧រូប៖

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

១- វរអគ្គានុរក្សថ្នាក់លេខ១ ថោ សាវ៉ាត់

២- វរអគ្គានុរក្សថ្នាក់លេខ២ ធឹម បូណា

៣- វរអគ្គានុរក្សថ្នាក់លេខ២ រីម ប៊ុនថាន

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** :

១- វរអគ្គានុរក្សថ្នាក់លេខ២ សោម បូរិន្ទ

២- វរអគ្គានុរក្សថ្នាក់លេខ២ ម៉ាន ម៉ន

៣- វរអគ្គានុរក្សថ្នាក់លេខ២ ធឹម ចាន់ភ៉ា

៤- វរអគ្គានុរក្សថ្នាក់លេខ២ ជា សូនី

នរោត្តមសីហមុនី

៣.ខ.ស. ២១១១.៩១៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០២១

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/១១២១/៨០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

នូវ

គ្រឿងឥស្សរិយយស ដល់មន្ត្រីរាជការនៃក្រសួងយុត្តិធម៌ ២៣រូប៖

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១- លោកជំទាវ ប៉ែន សុមេធា
២- លោក កេត ស៊ីណែត
៣- លោក សំ សុក្រជាតិ
៤- លោកស្រី ផន សុធាវី
៥- លោក សុង សុខភារម្យ
៦- លោក ជុំ ឃាង
៧- លោក អ៊ុម សហវុឌ្ឍី
៨- លោកស្រី រឿល ម៉ូរី
៩- លោកស្រី ហ៊ិន យ៉េកហ៊្វយ
១០- លោក សុខ អាត
១១- លោក ឃុន ចេស្តា

**ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១- លោកស្រី សៀង ហ៊ិន
២- លោកស្រី មាស សារ៉ានី

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

១- ឯកឧត្តម ប្អូន សុមុនី
២- លោកស្រី ពាវ ពឿន

**ឃ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**

១- ឯកឧត្តម យ៉ម ផារ៉ូត
២- លោក សៀ តុង
៣- លោកស្រី សុភិន វិសាល

**ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :**

លោកស្រី ជិន សុភាព

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

១- លោក ម៉ែន សុភាព ៣- លោកស្រី ជា សុខតារា

២- លោក សំ វេងសៀង

ឆ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ

លោកស្រី សារឿន សុពណ៌

៣៥៣.៧១១.៩៧០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០២១

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រី ប្រចាំការ**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា
លេខ: ០៩៥ រ.ស

# សេចក្តីប្រកាស
## ស្តីពី
## ការសម្រេចអំពីសុពលភាពនៃអាណត្តិ របស់តំណាងរាស្ត្រ នីតិកាលទី ៦ នៃរដ្ឋសភា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
-បានឃើញលទ្ធផលសម័យប្រជុំរដ្ឋសភាលើកទី ១ នីតិកាលទី ៦ នៃរដ្ឋសភា នាថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងរចនាសម្ព័ន្ធថ្នាក់ដឹកនាំរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
-យោងលិខិតលេខ ០៣៩/១១២១/លគ.គក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០២១ របស់គណបក្សប្រជាជនកម្ពុជា
-យោងសេចក្តីសម្រេចលេខ ៣១៩ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
-យោងតាមការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ដែលប្រជុំកាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១

## ប្រកាស

**ប្រការ ១.-**

ត្រូវបានសម្រេចអំពីសុពលភាពនៃអាណត្តិរបស់បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ នីតិកាលទី៦ នៃរដ្ឋសភា ឯកឧត្តម **អ៊ុន ម៉ុនហាន** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ ជំនួសឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ឈួន ញ៉ិល** ដែលបានទទួលមរណភាព។

**ប្រការ ២.-**

តំណាងរាស្ត្រដូចមានរាយនាមក្នុងប្រការ ១ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង។

**ប្រការ ៣.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ត្រូវទទួលភារកិច្ចបិទផ្សាយ សេចក្តីប្រកាសនេះ ក្នុងរដ្ឋសភា ផ្សព្វផ្សាយជាសាធារណៈ និងត្រូវចុះផ្សាយក្នុងរាជកិច្ចក្រោយពីបានធ្វើសច្ចាប្រណិធានចូលកាន់តំណែង។

ថ្ងៃព្រហស្បតិ៍ ៦ កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១
**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២២៨ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការបង្កើតតំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងកាដេរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានបង្កើតតំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងកាដេរ ដែលមានផ្ទៃដីទំហំ ១ ៦៤៣ (មួយពាន់ប្រាំមួយរយសែសិបបី) ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកក្រូចឆ្មារ និងស្រុកតំបែរ ខេត្តត្បូងឃ្មុំ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១ និងនិយាមកា(Datum: WGS1984) ភ្ជាប់ក្នុងឧបសម្ព័ន្ធ២ នៃអនុក្រឹត្យនេះ។

**មាត្រា២ .-**

ការបង្កើតតំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងកាដេរ មានគោលបំណងដូចតទៅៈ

- ធានាការថែរក្សានិងការពារសោភ័ណភាពធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ បរិស្ថាន និងវប្បធម៌
- ផ្តល់ផលិតផល និងសេវាកម្មធម្មជាតិ សម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- រក្សាលំនឹងបរិស្ថាន ការពារ និងអភិរក្សធនធានធម្មជាតិ
- បង្កើនតួនាទីប្រព័ន្ធអេកូឡូស៊ីសម្រាប់ជាផលប្រយោជន៍ដល់សង្គមជាតិគ្រប់ជំនាន់
- បង្កើននិងធានាការប្រើប្រាស់តំបន់ដីសើមប្រកបដោយភាពឈ្លាសវៃ
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋានក៏ដូចជាសាធារណជន ក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងកាដេរ។

**មាត្រា៣ .-**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រង តំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងកាដេរ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្តត្បូងឃ្មុំ និងសហគមន៍មូលដ្ឋានពាក់ព័ន្ធ ដើម្បីធានាកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ស្របតាមបទប្បញ្ញត្តិ នៃច្បាប់ជាធរមាន។ ក្រសួងបរិស្ថានត្រូវគាំទ្របច្ចេកទេស ហិរញ្ញវត្ថុ និងកសាងសមត្ថភាពដល់រដ្ឋបាលខេត្តត្បូងឃ្មុំ និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ ដោយប្រើប្រាស់មូលនិធិបរិស្ថាន និងសង្គម។

**មាត្រា៤ .-**

រដ្ឋបាលខេត្តត្បូងឃ្មុំ ត្រូវបង្កើតក្រុមការងារអចិន្ត្រៃយ៍មួយរបស់ខ្លួន ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងមន្ទីរ-អង្គភាពជំនាញពាក់ព័ន្ធ និងមានតួនាទីដឹកនាំ ថែរក្សា ការពារ និងប្រើប្រាស់ធនធានធម្មជាតិនៃតំបន់បឹងកាដេរឱ្យមាននិរន្តរភាព។ រដ្ឋបាលខេត្តត្បូងឃ្មុំ ត្រូវរៀបចំគម្រោងថវិកាសម្រាប់ដំណើរការរបស់ក្រុមការងារក្នុងកញ្ចប់ថវិការបស់រដ្ឋបាលខេត្ត។

**មាត្រា៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦** .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១១ កើត ខែ កត្ដិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០២១ ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ២ នៃអនុក្រឹត្យលេខៈ១២៨....អនក្រ.បក ចុះថ្ងៃទី.១៥....ខែវិច្ឆិកា....ឆ្នាំ២០២១

| និយាមការគោល តំបន់បឹងកាដេះ បឹងជីខ្មៅ | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ល.រ | X | Y | ល.រ | X | Y | ល.រ | X | Y |
| 1 | 585023 | 1347826 | 21 | 588671 | 1347555 | 41 | 590010 | 1351473 |
| 2 | 585840 | 1347828 | 22 | 588757 | 1347362 | 42 | 589695 | 1350960 |
| 3 | 585825 | 1348034 | 23 | 589064 | 1347469 | 43 | 589464 | 1350623 |
| 4 | 586216 | 1348146 | 24 | 589111 | 1347494 | 44 | 589192 | 1350953 |
| 5 | 586909 | 1348000 | 25 | 589177 | 1347676 | 45 | 588983 | 1350570 |
| 6 | 586879 | 1348040 | 26 | 589144 | 1347905 | 46 | 588631 | 1350516 |
| 7 | 587232 | 1348449 | 27 | 589248 | 1348250 | 47 | 588571 | 1350212 |
| 8 | 587328 | 1348264 | 28 | 589350 | 1348544 | 48 | 588549 | 1349876 |
| 9 | 587631 | 1348268 | 29 | 590275 | 1348259 | 49 | 588272 | 1349926 |
| 10 | 587995 | 1348455 | 30 | 590679 | 1347833 | 50 | 588291 | 1350295 |
| 11 | 588035 | 1348346 | 31 | 590890 | 1348274 | 51 | 588223 | 1350734 |
| 12 | 587785 | 1348261 | 32 | 591240 | 1348131 | 52 | 587791 | 1350780 |
| 13 | 587725 | 1347865 | 33 | 591255 | 1348430 | 53 | 587306 | 1350864 |
| 14 | 588030 | 1347804 | 34 | 591613 | 1348275 | 54 | 586841 | 1350941 |
| 15 | 588064 | 1347583 | 35 | 591631 | 1348665 | 55 | 586652 | 1350211 |
| 16 | 588358 | 1347492 | 36 | 592133 | 1348468 | 56 | 586098 | 1349549 |
| 17 | 588400 | 1347355 | 37 | 591954 | 1349279 | 57 | 586056 | 1348941 |
| 18 | 588437 | 1347367 | 38 | 591566 | 1349856 | 58 | 585729 | 1348390 |
| 19 | 588383 | 1347557 | 39 | 591254 | 1350531 | 59 | 585448 | 1348399 |
| 20 | 588525 | 1347623 | 40 | 590900 | 1351044 | 60 | 584976 | 1348073 |

| និយាមការគោល តំបន់បឹងស្រួល | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ល.រ | X | Y | ល.រ | X | Y | ល.រ | X | Y |
| 61 | 587850 | 1351320 | 64 | 588808 | 1351641 | 67 | 588004 | 1352462 |
| 62 | 588305 | 1351338 | 65 | 588960 | 1352072 | 68 | 587853 | 1352051 |
| 63 | 588573 | 1351508 | 66 | 588539 | 1352285 | 69 | 587755 | 1351656 |

| និយាមការគោល តំបន់បឹងស្ពែ | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ល.រ | X | Y | ល.រ | X | Y | ល.រ | X | Y |
| 70 | 589863 | 1351839 | 73 | 590134 | 1351934 | 76 | 589545 | 1352058 |
| 71 | 589979 | 1351556 | 74 | 589907 | 1352020 | 77 | 589307 | 1352407 |
| 72 | 590058 | 1351758 | 75 | 589829 | 1352180 | 78 | 589617 | 1351970 |

ឧបសម្ព័ន្ធ១នៃអនុក្រឹត្យលេខ ២២៨ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០២១

ផែនទីតំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងកាដេរ ស្ថិតនៅស្រុកក្រូចឆ្មារ និងស្រុកតំបែរ ខេត្តត្បូងឃ្មុំ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៥ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ស្ដីពីការកំណត់ផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ទំហំ ៣.២៣៩,៧ហិកតា ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ផ្ទៃដី ចំនួន ០២ (ពីរ) ទីតាំង មានទំហំសរុប ៦៣.២២១ ម$^2$ (ហុកសិបបីពាន់ ពីររយម្ភៃមួយ ម៉ែត្រក្រឡា) ស្ថិតនៅក្នុងសង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ដែលត្រូវបានកំណត់ដោយអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ស្ដីពីការកំណត់ផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ទំហំ ៣.២៣៩,៧ហិកតា ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ ដើម្បីធ្វើអនុបយោគពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ក្នុងនោះរួមមាន និយាមកាដូចខាងក្រោម៖

- ទីតាំងដី ទំហំ ១៦.៣៥០ ម² (ដប់ប្រាំមួយពាន់ បីរយហាសិប ម៉ែត្រក្រឡា) ស្ថិតនៅក្នុងសង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ៖

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| 1 | 481807.5484 | 1286292.3305 | 5 | 481966.7807 | 1286484.8200 |
| 2 | 481779.4786 | 1286344.6902 | 6 | 482000.5672 | 1286426.1157 |
| 3 | 481782.1038 | 1286356.5342 | 7 | 481902.4219 | 1286360.5295 |
| 4 | 481956.3851 | 1286486.9603 | 8 | 481807.5484 | 1286292.3305 |

- ទីតាំងដី ទំហំ ៤៦.៨៧១ ម² (សែសិបប្រាំមួយពាន់ ប្រាំបីរយចិតសិបមួយ ម៉ែត្រក្រឡា) ស្ថិតនៅក្នុងសង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ៖

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| 1 | 482024.4051 | 1286444.3330 | 6 | 482536.7341 | 1286829.4949 |
| 2 | 482103.8543 | 1286504.9250 | 7 | 482500.0096 | 1286893.7900 |
| 3 | 482207.1382 | 1286583.6950 | 8 | 481993.3885 | 1286514.6523 |
| 4 | 482313.8101 | 1286665.0480 | 9 | 481990.9508 | 1286502.9121 |
| 5 | 482426.4330 | 1286746.5721 | 10 | 482024.4051 | 1286444.3330 |

**មាត្រា ២:** ត្រូវបានធ្វើប្រទានកម្មទីតាំងដី ចំនួន០២ (ពីរ) ទីតាំង ទំហំសរុប ៦៣.២២១ម² (ហុកសិបបីពាន់ ពីររយម្ភៃមួយ ម៉ែត្រក្រឡា) ស្ថិតនៅក្នុងសង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ខាងលើ ជាកម្មសិទ្ធជូន លោក ជឹម ពិសី ដោយពន្ធ និងអាករផ្សេងៗជាបន្ទុករបស់រដ្ឋ។

**មាត្រា ៣:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible]......[illegible]......ខែ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible]... ខែ[illegible].... ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល៖***
*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា៤*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកំណត់ផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ទំហំ ៣.២៣៩,៧ ហិកតា ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ

## សម្រេច

**មាត្រា ១:** ត្រូវបានកាត់ផ្ទៃដីទំហំ ១៩២.៣០៩ ម៉ែ២ (មួយរយកៅសិបពីរពាន់ បីរយប្រាំបួន ម៉ែត្រក្រឡា) ស្ថិតនៅសង្កាត់ពញាពន់ និងសង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ដែលត្រូវបានកំណត់ក្នុងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកំណត់ផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ទំហំ ៣.២៣៩,៧ ហិកតា ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ ដើម្បីធ្វើអនុបយោគពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដូចមាននិយាមកាខាងក្រោម៖

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| ១ | 481568.451 | 1289417.869 | ១៥ | 481012.354 | 1289480.596 |
| ២ | 481580.349 | 1289484.399 | ១៦ | 481001.404 | 1289475.754 |
| ៣ | 481600.854 | 1289540.623 | ១៧ | 480989.855 | 1289470.670 |
| ៤ | 481626.651 | 1289592.217 | ១៨ | 480983.036 | 1289468.085 |
| ៥ | 481656.579 | 1289633.718 | ១៩ | 480971.153 | 1289464.300 |
| ៦ | 481622.620 | 1289632.132 | ២០ | 480963.678 | 1289462.273 |
| ៧ | 481582.226 | 1289626.361 | ២១ | 480956.936 | 1289460.790 |
| ៨ | 481547.581 | 1289620.167 | ២២ | 480944.329 | 1289458.355 |
| ៩ | 481495.314 | 1289608.905 | ២៣ | 480931.770 | 1289456.508 |
| ១០ | 481458.178 | 1289599.852 | ២៤ | 480908.153 | 1289453.255 |
| ១១ | 481335.429 | 1289568.546 | ២៥ | 480895.470 | 1289449.746 |
| ១២ | 481277.284 | 1289553.284 | ២៦ | 480856.480 | 1289438.959 |
| ១៣ | 481099.354 | 1289506.160 | ២៧ | 480919.928 | 1289127.570 |
| ១៤ | 481022.751 | 1289485.034 | | | |

**មាត្រា ២** : ត្រូវបានធ្វើប្រទានកម្មផ្ទៃដីទំហំ ១៩២.៣០៩ ម$^{២}$ (មួយរយកៅសិបពីរពាន់ បីរយប្រាំបួន ម៉ែត្រក្រឡា) ស្ថិតនៅសង្កាត់ពញាពន់ និងសង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ខាងលើ ជាកម្មសិទ្ធិជូន លោក ចេង ស៊្រុនហេង ដោយពន្ធ និងអាករផ្សេងៗជាបន្ទុករបស់រដ្ឋ។

**មាត្រា ៣** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ... ៥រោច ... ខែចេត្រ ... ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល៖*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៤*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៥៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការសម្រួលភារកិច្ច និងតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ០៦ /នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានឃើញអនុក្រឹត្យលេខ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល
- បានឃើញអនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍
- បានឃើញអនុក្រឹត្យលេខ២១ អនក្រ.បក ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## សម្រេច

**មាត្រា ១.-** សម្រួលភារកិច្ចជូនមន្ត្រីរាជការ ចំនួន **២រូប** ដូចមានរាយនាមខាងក្រោម៖

១-លោក **មៀច រុន** ពីអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ត្បូងឃ្មុំ ទៅជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ព្រះសីហនុ

២-លោក **ឡៅ លាងហេង** ពីប្រធានលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តក្រចេះ ទៅជាប្រធានលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តស្ទឹងត្រែង។

**មាត្រា ២.-** តែងតាំងមុខតំណែងមន្ត្រីរាជការចំនួន **៩រូប** ដូចមានរាយនាមខាងក្រោម៖

**ក.អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល**

១-លោក **យ៉េត រិទ្ធិយ៉ា** ជាអគ្គលេខាធិការរង

២-លោក **អុល រចនៈ** ជាប្រធាននាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ

**ខ.អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ភ្នំពេញ**

១-លោក **ទឹម សទ្ធារិទ្ធិ** ជាអគ្គលេខាធិការរង

២-លោក **សេង សុវណ្ណរិទ្ធ** ជាប្រធាននាយកដ្ឋានកិច្ចការមហាអយ្យការ

**គ.អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ត្បូងឃ្មុំ**

១-លោក **ឃិន សុក្រិត្យា** ជាអគ្គលេខាធិការរង

២-លោក **ថុល ចន្ថា** ជាប្រធាននាយកដ្ឋានកិច្ចការតុលាការ

៣-លោក **ឈាង សារ៉ាត់** ជាប្រធាននាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ

**ឃ.លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្ត**

១-លោក **ស្រ៊ី ម៉េងស្រីន** ជាប្រធានលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តកែប

២-លោកស្រី **ឆាន់ ស្រីមុំ** ជាប្រធានលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តក្រចេះ។

**មាត្រា ៣.-** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ និងមាត្រា២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: [illegible] អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរ និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១** ៖ ផ្ទេរ និងតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ទោ **សុខ សំណាង** អត្តលេខ ០២១២១ ពីស្នងការនគរបាលខេត្តតាកែវ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ទៅជាអគ្គនាយករងនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ។

**មាត្រា ២** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ[illegible] ខែ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ [illegible] ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥២៦ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា១.** បំពាក់មេដាយ**មាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ១៨រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានា នៅវត្តរតនវនារាមបន្ទាយឆ្មារ វត្តរតសាមគ្គីរស្មីព្រៃចង្ហា និងវត្តជម្ពូវណ្ណារាមក្បាលទន្សោង ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ចំណាយអស់ថវិកាសរុបចំនួន ៣២០ ៨៨៨ ដុល្លារអាម៉េរិក កន្លងមក ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម បណ្ឌិត អ៊ុក សោភ័ណ្ឌ
២- លោកជំទាវ ម៉ៅ ចាន់ថន
៣- ឯកឧត្តម ឈូក ប៊ុណ្ណា
៤- អ្នកម្នាង ពេជ្រ សំអាត
៥- លោកបណ្ឌិត ស សារិន
៦- លោកស្រី វឿន ដាលី
៧- លោក ជិន វីរៈ
៨- លោក កែវ យៀម

៩- លោក ស្វ សុវណ្ណារិទ្ធ

១០- លោក ស្វ សុវណ្ណាដារ៉ា

១១- លោក សេង សាម៉េង

១២- លោក ម៉ុក វុទ្ធី

១៣- លោក រៀម សុជាតិ

១៤- លោក សុខ សារតា

**មាត្រា២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៧ កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៥២៧ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា១.-** បំពាក់មេដាយ**មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនសប្បុរសជនចំនួន ៦រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានា នៅវត្តរតនវនារាមបន្ទាយឆ្មារ វត្តរតសាមគ្គីរង្សីព្រៃចង្ក្រា និងវត្តជម្ពូវណ្ណារាមក្បាលទន្សោង ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ចំណាយអស់ថវិកាសរុបចំនួន ៤៨១ ៧២០ ដុល្លារអាមេរិក កន្លងមក ដូចមានរាយនាមខាងក្រោម៖

១- លោក នៅ សូវទ្រី
២- លោក ឡឹកឡាវណ្ណ ច័ន្ទរិទ្ធីស័ក្តិ
៣- លោក នៅ និស្ស័យ
៤- លោក ផុង ធីរៈ

៥- លោក សេង សំរេច

៦- លោក ង៉ែង ចាន់ចាវ

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៧ កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥២៨ អនក្រ.តត

**អនុក្រឹត្យ**

**ស្តីពី**

**ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

**អាណត្តិទី១**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២០/០២១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.តត ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អាណត្តិទី១
- យោងតាមសំណើរបស់ទេសាភិបាលធនាគារជាតិនៃកម្ពុជា

**សម្រេច**

**មាត្រា១ .-**

ត្រូវបានតែងតាំង ឯកឧត្តម **ធេព តិយ៉ោរិទ្ធ** ជាសមាជិកក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ថែមលើមុខងារបច្ចុប្បន្ន ជំនួស ឯកឧត្តម **រស់ សីលវ៉ា**។

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៧ កើត ខែ កត្ដិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥២៨ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារា
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

### សម្រេច

**មាត្រា១.** បំពាក់មេដាយ**សុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ជូនលោក **ចាប ចាន់ណារិត** អនុប្រធានផ្នែក អគ្គលេខាធិការដ្ឋាននៃគណៈវិស្វករកម្ពុជា ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក។

**មាត្រា២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៧ កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១១៦ សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីបង្ការនិងបង្ក្រាបការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធនិងការប្រើប្រាស់សេវាទូរគមនាគមន៍ឆ្លងដែនខុសច្បាប់**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២១/៧៥៣ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីបង្ការនិងបង្ក្រាបការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធនិងការប្រើប្រាស់សេវាទូរគមនាគមន៍ឆ្លងដែនខុសច្បាប់ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ជា វ៉ាន់ដេត** | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ប្រធាន |
| ២. ឯកឧត្តម **វង្សៀង ស៊ុនលី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. ឯកឧត្តម **សំរិទ្ធ ឌី** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤. ឯកឧត្តម **ញឹម ខេមរា** | រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |

៥. ឯកឧត្តម **ជុន វ៉ាត** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ អនុប្រធាន

៦. ឯកឧត្តម **ថោង ចិន្តា** ប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា អនុប្រធានអចិន្ត្រៃយ៍

៧. ឯកឧត្តម **លីវ សុផាណារិទ្ធិ** អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក

៨. ឯកឧត្តម នាយឧត្តមសេនីយ៍ **ឆែ ស៊ីណារិទ្ធ** អគ្គស្នងការរងនគរបាលជាតិ សមាជិក

៩. ឯកឧត្តម **ម៉ាន់ ដានី** អគ្គាធិការនៃអគ្គាធិការដ្ឋាន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក

១០. ឯកឧត្តម ឧត្តមសេនីយ៍ឯក **សូខន បញ្ញារិទ្ធិ** អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ សមាជិក

១១. លោកឧត្តមសេនីយ៍ទោ **ម៉ៅ គន្ធា** អនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យា នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ សមាជិក

១២. លោក **ចេង ខ្សៀ** អភិបាលរងនៃគណៈអភិបាលខេត្តពោធិ៍សាត់ សមាជិក

១៣. លោក **ឆូ តា** អភិបាលរងនៃគណៈអភិបាលខេត្តបាត់ដំបង សមាជិក

១៤. លោកស្រី **ឡុញ ឈាង** អភិបាលរងនៃគណៈអភិបាលខេត្តប៉ៃលិន សមាជិក

១៥. លោក **ម៉ោ ម៉េងជួន** អភិបាលរងនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ សមាជិក

១៦. លោក **ហ្សួន វ៉ាន់និត** អភិបាលរងនៃគណៈអភិបាលខេត្តឧត្តរមានជ័យ សមាជិក

១៧. លោក **លី សារ៉ារិទ្ធ** អភិបាលរងនៃគណៈអភិបាលខេត្តព្រះវិហារ សមាជិក

១៨. លោក **ជា ថាវរិទ្ធ** អភិបាលរងនៃគណៈអភិបាលខេត្តស្ទឹងត្រែង សមាជិក

១៩. លោក **លន់ សុភាព** អភិបាលរងនៃគណៈអភិបាលខេត្តរតនគិរី សមាជិក

២០. លោក **ជាក់ ម៉េងហ៊ាង** អភិបាលរងនៃគណៈអភិបាលខេត្តមណ្ឌលគិរី សមាជិក

២១. លោក **ម៉ែន លីណាត** អភិបាលរងនៃគណៈអភិបាលខេត្តក្រចេះ សមាជិក

២២. លោក **ពាង ណារិទ្ធ** អភិបាលរងនៃគណៈអភិបាលខេត្តត្បូងឃ្មុំ សមាជិក

២៣. លោក **សេង សីលា** អភិបាលរងនៃគណៈអភិបាលខេត្តស្វាយរៀង សមាជិក

២៤. លោក **ឌុច គន្ធា** អភិបាលរងនៃគណៈអភិបាលខេត្តព្រៃវែង សមាជិក

២៥. លោក **ណុប ដារ៉ា** អភិបាលរងនៃគណៈអភិបាលខេត្តកណ្តាល សមាជិក

២៦. លោក **ខាន់ សុខា** អភិបាលរងនៃគណៈអភិបាលខេត្តតាកែវ សមាជិក

២៧. លោក **អ៊ឹង ឆាយ** អភិបាលរងនៃគណៈអភិបាលខេត្តកំពត សមាជិក

២៨. លោក **គង់ ទិតាណា** អភិបាលរងនៃគណៈអភិបាលខេត្តព្រះសីហនុ សមាជិក

២៩. លោក **សុខ សុទ្ធី** អភិបាលរងនៃគណៈអភិបាលខេត្តកោះកុង សមាជិក។

**ប្រការ២ .-**

គណៈកម្មការអន្តរក្រសួងដើម្បីបង្ការនិងបង្ក្រាបការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធនិងការប្រើប្រាស់សេវាទូរគមនាគមន៍ឆ្លងដែនខុសច្បាប់ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- បង្ការ បង្ក្រាប និងត្រួតពិនិត្យលើការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ និងការប្រើប្រាស់សេវាទូរគមនាគមន៍ឆ្លងដែន ដើម្បីធានាអធិបតេយ្យភាព ប្រសិទ្ធភាព សុវត្ថិភាព និងគុណភាពនៃការផ្តល់សេវាទូរគមនាគមន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំផែនការកែសម្រួលរាល់ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍អន្តរជាតិនៅតាមបណ្តោយព្រំដែននៃព្រះរាជាណាចក្រកម្ពុជា ដោយត្រូវបង្វែរឱ្យមកឆ្លងកាត់ច្រកទ្វារអ៊ីនធឺណិតជាតិ
- ដឹកនាំសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និង/ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដើម្បីស្រាវជ្រាវស៊ើបអង្កេត ទប់ស្កាត់ និងបង្ក្រាបការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ និងការប្រើប្រាស់សេវាទូរគមនាគមន៍ឆ្លងដែនខុសច្បាប់
- សម្របសម្រួលជាមួយបណ្តាប្រទេសជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជាលើការងារគ្រប់គ្រងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ និងការប្រើប្រាស់សេវាទូរគមនាគមន៍អន្តរជាតិ
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងៗទៀតដែលប្រមុខរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ៣ .-**

គណៈកម្មការអន្តរក្រសួងដើម្បីបង្ការនិងបង្ក្រាបការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធនិងការប្រើប្រាស់សេវាទូរគមនាគមន៍ឆ្លងដែនខុសច្បាប់ មានលេខាធិការដ្ឋានមួយជាសេនាធិការ។

សមាសភាពជាក់ស្តែង តួនាទីនិងភារកិច្ចនៃលេខាធិការដ្ឋានត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មការអន្តរក្រសួង។

**ប្រការ៤ .-**

អនុប្រធាន សមាជិក និងសមាសភាពលេខាធិការដ្ឋាននៃគណៈកម្មការអន្តរក្រសួងត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការអន្តរក្រសួង។ ប្រធានគណៈកម្មការអន្តរក្រសួងអាចអញ្ជើញសមាសភាពពាក់ព័ន្ធផ្សេងទៀតមកចូលរួមប្រជុំ តាមការចាំបាច់។

**ប្រការ៥ .-**

គណៈកម្មការអន្តរក្រសួងដើម្បីបង្ការនិងបង្ក្រាបការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធនិងការប្រើប្រាស់សេវាទូរគមនាគមន៍ឆ្លងដែនខុសច្បាប់ មានសិទ្ធិប្រើត្រារបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងការបំពេញតួនាទីនិងភារកិច្ចដូចមានចែងក្នុងសេចក្តីសម្រេចនេះ។

**ប្រការ៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣ រោច ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៦ សរ.ណន

**សារាចរណែនាំ**
**ស្តីពី**
**ការចូលរួមគោរពព្រះវិញ្ញាណក្ខន្ធព្រះសព**
**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានក្រុម ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ**
**នៃព្រះរាជាណាចក្រកម្ពុជា អតីតនាយករដ្ឋមន្ត្រីទី១ និងជាអតីតប្រធានរដ្ឋសភា**
**នៃព្រះរាជាណាចក្រកម្ពុជា**

ដោយ សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានក្រុម ឧត្តមប្រឹក្សាផ្ទាល់ **ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា អតីតនាយករដ្ឋមន្ត្រីទី១ និងជាអតីតប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដែល **ព្រះអង្គ** មានគុណបំណាច់ដ៏ធំធេងចំពោះ: **ជាតិ សាសនា ព្រះមហាក្សត្រ** ហើយព្រះអង្គបានយាងចូលព្រះទិវង្គត នៅថ្ងៃអាទិត្យ ៩រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ៩:៤០នាទីព្រឹក នៅប្រទេសបារាំង ត្រូវនឹងម៉ោង ៣:៤០នាទីរសៀល ម៉ោងនៅព្រះរាជាណាចក្រកម្ពុជា ដោយព្រះរោគាពាធ ក្នុងព្រះជន្មាយុ ៧៧ព្រះវស្សា រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ:

១- ប្រកាសថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២១ ជាថ្ងៃកាន់ទុក្ខជាផ្លូវការ ។

២- គ្រប់ក្រសួង ស្ថាប័ន សាលារៀន មន្ទីរពេទ្យរបស់រដ្ឋ ឯកជនទាំងអស់ និងមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ គ្រប់ទីវត្តអារាម ព្រមទាំងប្រជាជនទូទាំងប្រទេស ត្រូវបង្ហូតទង់ជាតិត្រឹមពាក់កណ្តាលនៃដងទង់ជាតិ នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២១ ។

៣- គ្រប់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ជាតិ និងឯកជនទាំងអស់ ត្រូវផ្អាកការសម្តែង និងចាក់ផ្សាយនូវទស្សនីយភាពផ្សេងៗ ដែលមានលក្ខណៈសប្បាយ៍តគ្រឹកគគ្រេង នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២១ ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ អន្តរជាតិ និងរដ្ឋបាលដែនដី គ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងជនរួមជាតិទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីជាកិច្ចចូលរួមមរណទុក្ខដ៏ក្រៀមក្រំបំផុតនេះ ។

ថ្ងៃសុក្រ ១៤រោច ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន
- គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាល រាជធានីខេត្ត
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..៣៦០....សហវ.....ប្រក

## ប្រកាស
## ស្តីពី
## ការបង្កើតអង្គភាពអនុវត្តគម្រោង សម្រាប់សមាសភាគទី១ ស្តីពីការលើកកម្ពស់ខ្សែច្រវ៉ាក់តម្លៃកសិកម្ម នៃគម្រោងប្រកួតប្រជែងខ្សែច្រវ៉ាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនុក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នូវនីតិវិធីរួមសម្រាប់ការគ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- យោងកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការ (Loan No. 4013-CAM/8389-CAM) ស្តីពីគម្រោងប្រកួតប្រជែងខ្សែច្រវ៉ាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២០ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ADB
- យោងតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.** _

ត្រូវបានបង្កើត "**អង្គភាពអនុវត្តគម្រោង**" (Project Implementing Unit) សម្រាប់អនុវត្តសមាសភាគទី១ ស្តីពីការលើកកម្ពស់ខ្សែច្រវ៉ាក់តម្លៃកសិកម្ម នៃគម្រោងប្រកួតប្រជែងខ្សែច្រវ៉ាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម។

**ប្រការ ២.** _

"**អង្គភាពអនុវត្តគម្រោង**" មានតួនាទី និងភារកិច្ចស្នូល ដូចខាងក្រោម៖

- ជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រង និងសម្របសម្រួលការអនុវត្តសមាសភាគទី១ ស្តីពីការលើកកម្ពស់ខ្សែច្រវ៉ាក់តម្លៃកសិកម្ម នៃគម្រោងប្រកួតប្រជែងខ្សែច្រវ៉ាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម
- គ្រប់គ្រង និងចាត់ចែងការងារហិរញ្ញវត្ថុ និងការផ្តល់ឥណទានសមាសភាគទី១ របស់គម្រោង
- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ការគ្រប់គ្រង និងអនុវត្តសមាសភាគទី១ របស់គម្រោង
- តាមដានពិនិត្យការអនុវត្តសមាសភាគទី១ និងស្នើឡើងនូវគោលការណ៍អនុវត្ត និងវិធានការដោះស្រាយរាល់បញ្ហាប្រឈមទៅនឹងការអនុវត្តសមាសភាគទី១របស់គម្រោង
- អនុវត្តតួនាទីផ្សេងទៀត ដូចមានចែងនៅក្នុង Standard Operating Procedures (SOPs), Project Administration Manual (PAM), និង General Operating Guidelines (GOG)។

**ប្រការ ៣.** _

"**អង្គភាពអនុវត្តគម្រោង**" ត្រូវដឹកនាំដោយនាយកគម្រោង ០១រូប ដែលជាមន្ត្រីជាន់ខ្ពស់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានអ្នកគ្រប់គ្រងគម្រោង ០១រូប សម្រាប់ជួយគ្រប់គ្រងកិច្ចការប្រចាំថ្ងៃ។

"**អង្គភាពអនុវត្តគម្រោង**" មានផ្នែកចំណុះចំនួន ០៤ ដូចខាងក្រោម÷

- ផ្នែកប្រតិបត្តិការ
- ផ្នែកលទ្ធកម្ម
- ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ
- ផ្នែករដ្ឋបាល និងការគាំទ្រទូទៅ

ផ្នែកនីមួយៗ ត្រូវដឹកនាំដោយប្រធាន ០១រូប និងមន្ត្រីជំនាញមួយចំនួន ជាជំនួយការ តាមការចាំបាច់។ អង្គការលេខរបស់ "**អង្គភាពអនុវត្តគម្រោង**" ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៤.** _

ថ្នាក់ដឹកនាំ និងមន្ត្រីដែលបំពេញការងារនៅ "**អង្គភាពអនុវត្តគម្រោង**" ត្រូវអនុវត្តតួនាទី និងភារកិច្ច ដូចមានចែងលម្អិតនៅក្នុង Standard Operating Procedures (SOPs), Project Administration Manual (PAM), និង General Operating Guidelines (GOG)។

**ប្រការ ៥.** _

សមាសភាពថ្នាក់ដឹកនាំ និងមន្ត្រីនៃ "**អង្គភាពអនុវត្តគម្រោង**" មានដូចខាងក្រោម÷

**ក. ថ្នាក់ដឹកនាំគម្រោង**

| | | |
|---|---|---|
| ១. ឯកឧត្តម | **ម៉ី ម៉ាន់** | នាយកគម្រោង |
| ២. លោក | **ប៉ូ សំអាង** | ប្រធានគ្រប់គ្រងគម្រោង |

**ខ.ផ្នែកប្រតិបត្តិការ** (AVCL-CL, ECL-CL, CGF, Safeguard, and Gender)

| | | |
|---|---|---|
| ១. លោកស្រី | **ឌុន បូនីតា** | មន្ត្រីឥណទានគម្រោង |
| ២. លោក | **ឡុន សុភាផល្លា** | មន្ត្រីឥណទានគម្រោង |
| ៣. លោក | **ឃុត តារាទិន័យ** | មន្ត្រីឥណទានគម្រោង |
| ៤. លោក | **គង់ ពុទ្ធី** | មន្ត្រីឥណទានគម្រោង |

**គ.ផ្នែកលទ្ធកម្ម**

| | | |
|---|---|---|
| ១. លោក | **ម៉ឿន សុវណ្ណារ៉ា** | មន្ត្រីលទ្ធកម្មគម្រោង |

**ឃ.ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ**

| | | |
|---|---|---|
| ១. លោកស្រី | **សាង សេរីវឌ្ឍនា** | មន្ត្រីហិរញ្ញវត្ថុ និងគណនេយ្យករគម្រោង |
| ២. លោក | **ឆែម លាបហេង** | ជំនួយការហិរញ្ញវត្ថុ និងគណនេយ្យករគម្រោង |

**ង. ផ្នែករដ្ឋបាល និងគាំទ្រទូទៅ**

| | | |
|---|---|---|
| ១. លោកស្រី | **កែន សឿម** | មន្ត្រីរដ្ឋបាលគម្រោង |
| ២. លោក | **ប៉ូ ស៊ាងហាន** | ជំនួយការកិច្ចការទូទៅ |

**ប្រការ ៦.** _

មន្ត្រីដែលបម្រើការងារនៅ "**អង្គភាពអនុវត្តគម្រោង**" អាចជាមន្ត្រីស្ថិតក្រោមក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬមន្ត្រីជាប់កិច្ចសន្យា។

នាយកគម្រោងមានសិទ្ធិជ្រើសរើសទីប្រឹក្សា និងបុគ្គលិកជាប់កិច្ចសន្យា ដើម្បីគាំទ្រដល់ការអនុវត្តតួនាទី និងភារកិច្ចរបស់ "**អង្គភាពអនុវត្តគម្រោង**" ដូចមានចែងក្នុងប្រការ២ តាមការចាំបាច់។

**ប្រការ ៧.** _

ប្រាក់ឧបត្ថម្ភផ្សេងៗរបស់ថ្នាក់ដឹកនាំ, មន្ត្រី, និងបុគ្គលិកជាប់កិច្ចសន្យារបស់ "**អង្គភាពអនុវត្តគម្រោង**" ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់នាយកគម្រោង។

**ប្រការ ៨.** _

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៩.** _

នាយកខុទ្ទកាល័យ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ប្រតិភូរាជរដ្ឋាភិបាល ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងអភិវឌ្ឍន៍ជនបទ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធ ប្រកាសលេខ**........................

ថ្ងៃ........................ខែ........................ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ចុះថ្ងៃទី............ខែ............ឆ្នាំ២០២១

អង្គការលេខសមាសភាគទី១របស់ **គ.ប្រ.ត.ស.ក.**



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.៣៦៥......សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ដំឡើងនាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុលទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ត្រូវបានបង្កើត ក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលសរសេរជាអក្សរកាត់ថា **ក.ប.ព.** ដើម្បីដឹកនាំសម្របសម្រួល និងជំរុញការកសាង និងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងឌីជីថល របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រកបដោយដវភាព សង្គតិភាព និងសុខដុមភាព សំដៅកសាងទំនុកចិត្ត និងភាពជឿជាក់លើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញ-វត្ថុ ព្រមទាំងចូលរួមចំណែកដល់ការកសាង និងអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា។

## ជំពូកទី២

## តួនាទីនិងភារកិច្ចរបស់ ក.ប.ព

**ប្រការ២.-**

**ក.ប.ព.** មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- កំណត់ចក្ខុវិស័យ និងគោលការណ៍អភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដឹកនាំ និងតម្រង់ទិសលើការរៀបចំផែនការមេ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីកសាង និងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដឹកនាំ និងជំរុញការកសាងនិងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដឹកនាំ និងជំរុញការកសាងនិងការអភិវឌ្ឍភាពជាអ្នកដឹកនាំនិងអភិបាលកិច្ចឌីជីថលនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សម្រេច និងដាក់ឱ្យអនុវត្តស្តង់ដារបច្ចេកទេស ស្តង់ដារសន្តិសុខឌីជីថល ស្តង់ដារនីតិវិធីប្រតិបត្តិ និងសេចក្តីណែនាំបច្ចេកទេសបច្ចេកវិទ្យាព័ត៌មានផ្សេងៗ
- ដឹកនាំ សម្របសម្រួល និងដោះស្រាយការងារនិងបញ្ហាផ្សេងៗ ដែលមានលក្ខណៈអន្តរអង្គភាពពាក់-ព័ន្ធនឹងគម្រោងបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- កៀរគរធនធានហិរញ្ញវត្ថុ, ធនធានបច្ចេកទេស និងធនធានមនុស្ស ក្នុងបុព្វហេតុអភិវឌ្ឍបច្ចេកវិទ្យា-ព័ត៌មាន និងឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ពិនិត្យ និងសម្រេចលើការស្នើសុំថវិកាគាំទ្រគម្រោងបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ជំរុញលើកទឹកចិត្ត និងគាំទ្រការចូលរួមលើកស្ទួយការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង ឌីជីថល របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បំពេញតួនាទីនិងភារកិច្ចដទៃទៀត តាមការប្រគល់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៣
## សមាសភាព ក.ប.ព.

**ប្រការ៣.-**

**ក.ប.ព.**មានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| - ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ រូប | អនុប្រធានប្រចាំការ |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | អនុប្រធាន |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ | អនុប្រធាន |
| - អនុរដ្ឋលេខាធិការពាក់ព័ន្ធមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - អគ្គាធិការនៃអគ្គាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - នាយកវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ **ក.ប.ព.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ ក.ប.ព.

**ប្រការ៤.-**

អនុប្រធាននិងសមាជិក **ក.ប.ព.**ត្រូវចូលរួមកិច្ចប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន។

ក្នុងករណីអវត្តមានឬមានធុរៈ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធាន ឬអនុប្រធានប្រចាំការ ឱ្យកោះអញ្ជើញ និងដឹកនាំកិច្ចប្រជុំ។

**ប្រការ៥.-**

**ក.ប.ព**មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្នុងការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។

**ប្រការ៦.-**

**ក.ប.ព.** មានក្រុមការងារបច្ចេកទេសមួយជាសេនាធិការ នៅក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន។

ក្រុមការងារបច្ចេកទេស **ក.ប.ព.** មានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - អនុប្រធានប្រចាំការនៃ **ក.ប.ព.** | ប្រធាន |

- ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គលេខាធិការដ្ឋានក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានប្រចាំការ
- ប្រធានអង្គភាព ឬអនុប្រធានប្រចាំការទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មាន នៃអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយចំនួន អនុប្រធាន
- ប្រធាននាយកដ្ឋានទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មាន នៃអគ្គនាយកដ្ឋាន ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- ប្រធានអង្គភាពទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មាន នៃអង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- តំណាងក្រុមការងារទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក។

សមាសភាពជាក់ស្តែងនៃក្រុមការងារបច្ចេកទេស **ក.ប.ព.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៧.-**

ក្រុមការងារបច្ចេកទេស **ក.ប.ព.** មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- សម្របសម្រួលលើការងារអនុវត្តផែនការមេ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីកសាងនិងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សហការការងារជាមួយនឹងអង្គភាពចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពាក់ព័ន្ធការកសាងនិងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- កសាង អភិវឌ្ឍ និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងថ្នាលឌីជីថលសម្រាប់ការប្រើប្រាស់រួម
- រៀបចំស្តង់ដារបច្ចេកទេស ស្តង់ដារសន្តិសុខឌីជីថល ស្តង់ដារនីតិវិធីប្រតិបត្តិ និងសេចក្តីណែនាំបច្ចេកទេសបច្ចេកវិទ្យាព័ត៌មានផ្សេងៗ
- ផ្តួចផ្តើម និងកំណត់កម្មវត្ថុនៃការសិក្សាស្រាវជ្រាវ និងរៀបចំទស្សនកិច្ចសិក្សាទាំងក្នុងប្រទេស និងក្រៅប្រទេស ដើម្បីទាញយកបទពិសោធន៍និងប្រមូលធាតុចូលសំខាន់ៗពាក់ព័ន្ធនឹងការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងឌីជីថល
- រៀបចំឱ្យមានការបណ្តុះបណ្តាល ការពង្រឹងសមត្ថភាព និងការចែករំលែកចំណេះដឹងទៅលើការអភិវឌ្ឍ ការប្រតិបត្តិ និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលនានារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំផែនការវិនិយោគ ដើម្បីគាំទ្រដល់ការអនុវត្តផែនការមេបច្ចេកវិទ្យាព័ត៌មាន និងឌីជីថល
- ពិនិត្យ ពិភាក្សា វាយតម្លៃ និងធ្វើអាទិភាពូបនីយកម្មគម្រោងបច្ចេកវិទ្យាព័ត៌មានដែលបានស្នើក្នុងក្របខណ្ឌការងាររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជានាប្រសិទ្ធភាពនៃថវិកា និងសង្គតិភាពជាមួយផែនការមេបច្ចេកវិទ្យាព័ត៌មាន និងឌីជីថល
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការមេ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ដោយត្រូវរៀបចំរបាយការណ៍ជូន **ក.ប.ព.**

- បំពេញតួនាទីនិងភារកិច្ចដទៃទៀត តាមការប្រគល់របស់ប្រធានក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៨.-**

ក្រុមការងារបច្ចេកទេស **ក.ប.ព.** មាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាន។ លេខាធិការដ្ឋានក្រុមការងារបច្ចេកទេស **ក.ប.ព.** បំពេញមុខងារជាសេនាធិការជូនក្រុមការងារបច្ចេកទេស **ក.ប.ព.** លើការងាររដ្ឋបាល និងបច្ចេកទេស។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**ប្រការ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥០៦២ សហវ.ប្រក

ថ្ងៃ អង្គារ ១០ កើត ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០២១

# ប្រកាស
## ស្តីពី
## ការកែសម្រួលចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាចំណាយចរន្តសារបស់រដ្ឋបាលថ្នាក់ជាតិ សម្រាប់ក្រសួងចំនួនដប់ពីរ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋនៅតាមក្រសួង-ខេត្ត-ក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៧៧២ សហវ.ប្រក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញប្រកាសលេខ ៦៦២ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០២០ ស្តីពីការកែសម្រួលចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១ .–**

ត្រូវបានអនុញ្ញាតឱ្យកែសម្រួលចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ សម្រាប់ក្រសួងចំនួនដប់ពីរ ដូចមានចែងក្នុង**ឧបសម្ព័ន្ធស្តីពី “ការកែសម្រួលចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ សម្រាប់ក្រសួងចំនួនដប់ពីរ”** ភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ ២ .–**

អគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចរៀបចំបង្កើតបន្ថែម ឬកែសម្រួលចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិកា តាមតម្រូវការចាំបាច់សម្រាប់ការអនុវត្តថវិកាប្រចាំឆ្នាំ ហើយនៅចុងឆ្នាំនីមួយៗ ត្រូវរៀបចំប្រកាសកែសម្រួល ឬប្រកាសបំពេញបន្ថែមចំណាត់ថ្នាក់រដ្ឋបាលដែលបានបង្កើតបន្ថែមនោះដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យ និងចុះហត្ថលេខា។

**ប្រការ ៣ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤ .–**

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ “ដើម្បីអនុវត្ត”
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ...០៧៩... សហវ.

# ប្រកាស
## ស្តីពី
## ការកំណត់ប្រភព និងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់និយ័តករធានារ៉ាប់រងកម្ពុជា

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
### និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញប្រកាសលេខ ០៩៨ សហវ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៧ស្តីពីការផ្តល់អាជ្ញាបណ្ណជូនក្រុមហ៊ុនធានារ៉ាប់រងទូទៅ ឬអាយុជីវិត
- យោងតាមការចាំបាច់សម្រាប់កិច្ចដំណើរការរបស់និយ័តករធានារ៉ាប់រងកម្ពុជា

ទំព័រ ।

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់ប្រភព និងនីតិវិធីក្នុងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់និយ័តករធានារ៉ាប់រងកម្ពុជា ប្រកបដោយតម្លាភាព និងគណនេយ្យភាព ដើម្បីធានានូវប្រសិទ្ធភាពនៃកិច្ចដំណើរការរបស់ **និយ័តករធានារ៉ាប់រងកម្ពុជា** (ន.ធ.ក.)។

**ប្រការ ២.-**

វាក្យស័ព្ទដែលប្រើក្នុងប្រកាសនេះមាននិយមន័យដូចខាងក្រោម÷

- **ក្រុមហ៊ុនធានារ៉ាប់រង** សំដៅដល់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច និងក្រុមហ៊ុនធានារ៉ាប់រងបន្ត
- **គ្រឹះស្ថានធានារ៉ាប់រង** សំដៅដល់ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង និងក្រុមហ៊ុនគណនាហានិភ័យធានារ៉ាប់រង ។

## ជំពូកទី ២

## ប្រភពធនធានហិរញ្ញវត្ថុ

**ប្រការ ៣.-**

**ន.ធ.ក.** មានប្រភពធនធានហិរញ្ញវត្ថុមកពី÷

- ប្រាក់ភាគទាន ០.៥% ដែលក្រុមហ៊ុនត្រូវបង់ជូននិយ័តករធានារ៉ាប់រងកម្ពុជាសម្រាប់ទ្រទ្រង់កិច្ចដំណើរការរបស់និយ័តករធានារ៉ាប់រងកម្ពុជា
- កម្រៃអាជ្ញាបណ្ណ វិញ្ញាបនប័ត្រ ការចុះបញ្ជីនិងសោហ៊ុយទម្រង់ការលើការពិនិត្យវាយតម្លៃពាក្យស្នើសុំអាជ្ញាបណ្ណ វិញ្ញាបនប័ត្រ ការអនុញ្ញាត ការចុះបញ្ជីនិងការផ្តល់សេវាផ្សេងៗដល់គ្រឹះស្ថានធានារ៉ាប់រងនិងគ្រឹះស្ថានសោធនឯកជន
- កម្រៃពីការផាកពិន័យអន្តរការណ៍លើបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យធានារ៉ាប់រងនិងសោធនឯកជន
- ប្រភពផ្សេងៗ ។

## ជំពូកទី៣

## ការប្រើប្រាស់ធនធានហិរញ្ញវត្ថុ

**ប្រការ ៤.-**

ធនធានហិរញ្ញវត្ថុរបស់ **ន.ធ.ក.** ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់តាមគោលដៅដូចខាងក្រោម÷

- សម្រាប់ទ្រទ្រង់ដំណើរការរបស់និយ័តករធានារ៉ាប់រងកម្ពុជា (**ន.ធ.ក.**)

- សម្រាប់គោលដៅផ្សេងទៀតតាមការណែនាំពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

**ប្រការ ៥.-**

ធនធានសម្រាប់ទ្រទ្រង់ដំណើរការរបស់ **ន.ធ.ក.** ត្រូវបានបែងចែកដូចខាងក្រោម÷

- ប្រាក់ឧបត្ថម្ភជីវភាព
- ប្រាក់ឧបត្ថម្ភមុខងារ
- ប្រាក់រង្វាន់សមិទ្ធកម្ម
- មូលនិធិអភិវឌ្ឍស្ថាប័ននិយ័តករ ។

**ប្រការ ៦.-**

ប្រាក់ឧបត្ថម្ភជីវភាពត្រូវផ្តល់ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ ឬបុគ្គលិកនៃ **ន.ធ.ក.** ដែលមកបំពេញការងារទៀងទាត់ តាមមុខងារប្រកបដោយគុណភាពនិងផលិតភាពទៅតាមសន្ទស្សន៍និងមេគុណសមាមាត្រដូចមានកំណត់ក្នុងតារាងដូចខាងក្រោម÷

| ល.រ | តួនាទី | សន្ទស្សន៍មេគុណសមាមាត្រ |
|---|---|---|
| ១ | អគ្គនាយក | ៤,០០ |
| ២ | អគ្គនាយករង | ៣,៥០ |
| ៣ | ប្រធាននាយកដ្ឋាន | ៣,០០ |
| ៤ | អនុប្រធាននាយកដ្ឋាន | ២,៥០ |
| ៥ | ប្រធានការិយាល័យ | ២,០០ |
| ៦ | អនុប្រធានការិយាល័យ | ១,៥០ |
| ៧ | មន្ត្រី | ១,០០ |

**ប្រការ ៧.-**

ប្រាក់ឧបត្ថម្ភមុខងារត្រូវបានផ្តល់ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ ឬបុគ្គលិកនៃ **ន.ធ.ក.** ដែលបំពេញមុខងារពាក់ព័ន្ធនឹងការងារដឹកនាំ ការងារកែទម្រង់ ការងារគោលនយោបាយ ការងារសិក្សាស្រាវជ្រាវ ការងាររៀបចំច្បាប់និងបទប្បញ្ញត្តិនានា ការងារចូលរួមអនុវត្តគម្រោង និងក្រុមការងារជំនាញផ្សេងៗ តាមសន្ទស្សន៍មេគុណសមាមាត្រដូចមានកំណត់ក្នុងតារាងខាងក្រោម÷

| ល.រ | តួនាទី | សន្ទស្សន៍មេគុណសមាមាត្រ |
|---|---|---|
| ១ | អគ្គនាយក | ៥,០០ |
| ២ | អគ្គនាយករង | ៤,០០ |
| ៣ | ប្រធាននាយកដ្ឋាន | ៣,០០ |

| | | |
|---|---|---|
| ៤ | អនុប្រធាននាយកដ្ឋាន | ២,៥០ |
| ៥ | ប្រធានការិយាល័យ | ២,០០ |
| ៦ | អនុប្រធានការិយាល័យ | ១,៥០ |
| ៧ | មន្ត្រី | ១,០០ |

គម្រោងត្រូវមានទំហំការងារដែលត្រូវអនុវត្តក្នុងរយៈពេលចាប់ពីមួយឆ្នាំឡើងទៅ។ សម្រាប់ទំហំការងារដែលត្រូវអនុវត្តតិចជាងរយៈពេលមួយឆ្នាំ ត្រូវតែបង្កើតត្រឹមតែកម្រិតនៃក្រុមការងារ។ សម្រាប់ទំហំការងារដែលត្រូវអនុវត្តតិចជាងរយៈពេល ៣(បី)ខែ ត្រូវអនុវត្តក្នុងក្របខណ្ឌការងារប្រចាំថ្ងៃធម្មតា។

ថ្នាក់ដឹកនាំ មន្ត្រីរាជការ ឬបុគ្គលិកម្នាក់ៗអាចចូលរួមអនុវត្តការងារក្នុងគម្រោង ឬក្រុមការងារលើសពីមួយបានគិតទាំងគម្រោងជាមួយដៃគូអភិវឌ្ឍន៍ គម្រោងមូលនិធិផ្សេងៗ និងសមាជិកភាពនៃក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬមន្ត្រីត្រួតពិនិត្យ ប៉ុន្តែអនុញ្ញាតឱ្យទទួលប្រាក់ឧបត្ថម្ភមុខងារបានតែមួយប៉ុណ្ណោះ។

ក្នុងករណីមានជំនាញពិសេសចាំបាច់ ដែលជាក់ស្តែងតម្រូវឱ្យមានការផ្តល់ប្រាក់ឧបត្ថម្ភមុខងារខ្ពស់ គណៈកម្មការវាយតម្លៃសមិទ្ធកម្មរបស់និយ័តករធានារ៉ាប់រងកម្ពុជា អាចពិនិត្យនិងសម្រេចលើសំណើផ្តល់ប្រាក់ឧបត្ថម្ភតាមសន្ទស្សន៍ណាមួយក្នុងចំណោមសន្ទស្សន៍ទាំង៧ដែលបានកំណត់ខាងលើ។

**ប្រការ ៨.-**

ប្រាក់រង្វាន់សមិទ្ធកម្មត្រូវបានផ្តល់ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ ឬបុគ្គលិកដែលសម្រេចបានផលលើសគោលដៅកំណត់ដូចជា ការបង្កើតឱ្យមានផលចំណេញថវិកា ការសម្រេចលទ្ធផលការងារបានមុនផែនការកំណត់ ការសន្សំសំចៃថវិកាបានដោយចំណាយតិចជាងគោលការណ៍កំណត់។ ប្រាក់រង្វាន់សមិទ្ធកម្មត្រូវផ្តល់ប្រចាំត្រីមាស ឬឆមាស ឬឆ្នាំ ទៅតាមពេលវេលាជាក់ស្តែងដែលបានកំណត់សម្រាប់ការវាស់វែងសមិទ្ធកម្ម និងត្រូវបានកំណត់ដោយផ្អែកលើការសម្រេចលទ្ធផលការងារលើសគោលដៅ។

**ប្រការ ៩.-**

មូលនិធិអភិវឌ្ឍស្ថាប័ននិយ័តករត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់តាមមុខសញ្ញាចំណាយដូចខាងក្រោម÷

១. ចំណាយចរន្ត ÷ ទំនិញ សេវា និងបន្ទុកបុគ្គលិក សម្រាប់កិច្ចដំណើរការប្រចាំថ្ងៃរបស់និយ័តករ។

២. ចំណាយវិនិយោគ÷ ប្រព័ន្ធបច្ចេកវិទ្យាព័តមាន, ទីតាំងនិងអគារសម្រាប់បំពេញការងាររបស់និយ័តករ និងការវិនិយោគផ្សេងៗសម្រាប់អភិវឌ្ឍវិស័យធានារ៉ាប់រង។

៣. ចំណាយសង្គម ÷ ករណីមន្ត្រីនិងថ្នាក់ដឹកនាំជួបគ្រោះថ្នាក់ ឈឺស្កាត់ ទទួលមរណៈភាព និងជួបគ្រោះមហន្តរាយជាដើម និងកម្មវិធីសង្គមនានា។

ទំព័រ ៤

៤. ចំណាយផ្សេងៗ ÷ ចំណាយចាំបាច់ក្រៅពីគោលដៅចំណាយខាងលើ។

## ជំពូកទី៥
## យន្តការ និងនីតិវិធីត្រួតពិនិត្យ

**ប្រការ ១០.-**

និយ័តករធានារ៉ាប់រងកម្ពុជា ត្រូវបង្កើត "គណៈកម្មការវាយតម្លៃសមិទ្ធកម្ម" ដែលសរសេរអក្សរកាត់ថា **គ.វ.ស.** ដោយមានតួនាទីនិងភារកិច្ចដូចខាងក្រោម÷

- ពិនិត្យនិងវាយតម្លៃសមិទ្ធកម្មរបស់មន្ត្រីនៃ **ន.ធ.ភ.** សម្រាប់ផ្តល់ប្រាក់ឧបត្ថម្ភ
- រៀបចំនិងស្នើឡើងនូវផែនការផ្តល់ប្រាក់ឧបត្ថម្ភដល់មន្ត្រីនៃ **ន.ធ.ភ.** ជូនប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ។

**ប្រការ ១១.-**

**គ.វ.ស.** ត្រូវមានសមាភាពដូចខាងក្រោម÷

| | |
|---|---|
| ១. អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា | ប្រធាន |
| ២. អគ្គនាយករង ១រូប ឬច្រើនរូប | អនុប្រធាន |
| ៣. ប្រធាននាយកដ្ឋាន/ប្រធានលេខាធិការដ្ឋាន | សមាជិក |
| ៤. ប្រធានការិយាល័យបុគ្គលិក | លេខាធិការ។ |

សមាសភាពជាក់ស្តែងនៃ **គ.វ.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

**ប្រការ ១២.-**

អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា អាចបង្កើតក្រុមការងារវាយតម្លៃសមិទ្ធកម្មរបស់នាយកដ្ឋានក្រោមឱវាទនៃនិយ័តរធានារ៉ាប់រងកម្ពុជា ។

**ប្រការ ១៣.-**

និយ័តរធានារ៉ាប់រងកម្ពុជា ត្រូវរៀបចំគម្រោងចំណូល ចំណាយប្រចាំឆ្នាំ ឱ្យបានច្បាស់លាស់ដើម្បីស្នើសុំការសម្រេចរបស់ប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

**ប្រការ ១៤.-**

អង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ត្រូវអនុវត្តសវនកម្មប្រចាំឆ្នាំដើម្បីត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្មនៃការគ្រប់គ្រង ការប្រើប្រាស់និងការចាត់ចែងធនធានរបស់ **ន.ធ.ភ.** ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ ១៥.-**

ប្រកាសនេះ មានអានុភាពអនុវត្តចាប់ពីខែមករា ឆ្នាំ២០២២ ។

**ប្រការ ១៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៧.-**

អគ្គលេខាធិការនៃ **អ.ស.ហ.** អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា អគ្គនាយកនៃនិយ័តករ ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្រុមហ៊ុនធានារ៉ាប់រង និង បុគ្គលពាក់ព័ន្ធត្រូវទទួលអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ១២ ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ប្រការ៥ .-**

ម្ចាស់ទីតាំងត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ មកក្រសួងរ៉ែ និងថាមពល មុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងទីតាំងវេចខ្ចប់ឧស្ម័នអិល ភី ជី ជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការទីតាំងវេចខ្ចប់ឧស្ម័នអិល ភី ជី នេះ។

**ប្រការ៦ .-**

ម្ចាស់ទីតាំងត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យបរិមាណឧស្ម័នឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពល។

**ប្រការ៧ .-**

ម្ចាស់ទីតាំងត្រូវដាក់សំណើសុំការអនុញ្ញាតដំណើរការមកក្រសួងរ៉ែ និងថាមពល ចំពោះពោងឧស្ម័នឥន្ធនៈ ថ្មីដែលបានសាងសង់បន្ថែម នៅពេលបានសាងសង់រួចជាស្ថាពរ។

**ប្រការ៨ .-**

ម្ចាស់ទីតាំងត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងទីតាំងវេចខ្ចប់ឧស្ម័នអិល ភី ជី មានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩ .-**

ម្ចាស់ទីតាំងត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃទីតាំងវេចខ្ចប់ឧស្ម័នអិល ភី ជី របស់ខ្លួន។

**ប្រការ១០ .-**

ម្ចាស់ទីតាំងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពល រយៈពេល ១ (មួយ) ខែ យ៉ាងតិចមុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការម្ចាស់ទីតាំងជាស្ថាពរ។



៨៥

**ប្រការ១១ ...**

ប្រកាសនេះ មានរយៈពេលសុពលភាព ស្របតាមរយៈពេលសុពលភាពនៃលិខិតអនុញ្ញាតដំណើរការទីតាំងវេចខ្ចប់ឧស្ម័នអិល ភី ជី លេខ ០៥.០៤.រថ.អប៊ក.លអ..... ចុះថ្ងៃទី..០៤...ខែ..វិច្ឆិកា...ឆ្នាំ២០២០ របស់ក្រសួងរ៉ែនិងថាមពល និងអាចពន្យារបន្តបាន ស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២ ...**

ដោយប្រកាសរួមលេខ ១២៨ សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរ៉ែ និងថាមពល ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ពុំទាន់មានចែងពីកម្រៃសេវាសាធារណៈដែលត្រូវបង់សម្រាប់លិខិតអនុញ្ញាតដំណើរការទីតាំងវេចខ្ចប់ឧស្ម័ន អិល ភី ជី ម្ចាស់ទីតាំងនឹងតម្រូវឱ្យបង់កម្រៃសេវាសាធារណៈក្រោយមានការចែងពីកម្រៃសេវានេះ។

**ប្រការ១៣ ...**

ក្នុងករណីទីតាំងវេចខ្ចប់ឧស្ម័នអិល ភី ជី នេះ ផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ (ដប់ពីរ) ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការទីតាំងវេចខ្ចប់ឧស្ម័នអិល ភី ជី លេខ.០៥០៤.រថ.អប៊ក.លអ.. ចុះថ្ងៃទី..០៤...ខែ.វិច្ឆិកា....ឆ្នាំ២០២០.. នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៤ ...**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាតអគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលរាជធានីភ្នំពេញ និងក្រុមហ៊ុន **សេះមាស អ៊ីមផត អិចផត ខនស្រ្តាក់សិន & ឌីវេឡុបមេន គ្រុប** (SES MEAS IMPORT EXPORT CONSTRUCTION & DEVELOPMENT GROUP CO., LTD.) ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ......៤រោច.....ខែកត្តិក...ឆ្នាំជូត..ទោស័ក.ព.ស. ២៥៦៤
ធ្វើនៅភ្នំពេញ ថ្ងៃទី....០៤.... ខែ...វិច្ឆិកា.... ឆ្នាំ២០២០
**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចប្រការ១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០៥០៦.រ៧.អាប្រក.ប្រក

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
# លេខ ០៥.០៦.រ៧.អាប្រក.លអរ ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០២០

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បកចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពលនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ របស់លោកស្រី ព្រំ សុផាណា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈដែលមានស្លាកយីហោ ដេប៉ូតេលា សម្បត្តិមានហេង គុណាធីដូន ស្ថិតនៅភូមិបឹងឈូក សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ របស់លោកស្រី ព្រំ សុផាណា (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមប្រកាសលេខ ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធររាជធានីភ្នំពេញ
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមសារាចរលេខ ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ នូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. កបំពង់ទទួលប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧ ម៉ែត្រពីអគារ
២. បំពង់ខ្យល់ត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ ម៉ែត្រពីព្រំដីស្ថានីយ
៣. ត្រូវបំពាក់គន្លឹះអាសន្នជាប់ទូចាក់ប្រេងឥន្ធនៈនីមួយៗ និងគន្លឹះអាសន្នរួម
៤. ត្រូវគូសគំនូសសញ្ញាសម្រាប់ចំណតរថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ
៥. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក ។

**ប្រការ៥.–.**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្ដីណែនាំរបស់ក្រសួងរ៉ែ និងថាមពល ក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.–.**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.–.**

ម្ចាស់ស្ថានីយត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្ដាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្ដាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.–.**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការ ចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយឱ្យមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.–.**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.–.**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែនិងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.–.**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយលេខ..០៥០៦ រ៉ែ.អ.ប្រក.ណរ.....ចុះថ្ងៃទី..៤..................ខែ..វិច្ឆិកា......ឆ្នាំ២០២០...............របស់ក្រសួងរ៉ែនិងថាមពលនិងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.–.**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ០៥០៦ រ៉ែ.អ.ប្រក.ណរ ចុះថ្ងៃទី....៤.........ខែ...វិច្ឆិកា.........ឆ្នាំ២០២០....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការប្រធានមន្ទីររ៉ែ និងថាមពលរាជធានីភ្នំពេញ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.ពុធ.៤.រោច.....ខែ.កត្តិក......ឆ្នាំជូត.ទោស័ក.ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..៤.....ខែ.វិច្ឆិកា...ឆ្នាំ២០២០.

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ_សែម**

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

-សាលារាជធានីភ្នំពេញ

-ដូចប្រការ១៣

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០៥០៣៧.ឥ.អប្រក.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ
លេខ ០៥០៣៧.ឥ.អប្រក.លអអ ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០២០

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ របស់លោកស្រី ឡាំ សុភ័ក្រ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១**.-

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈឃើហោ **ស្ថានីយប្រេងឥន្ធនៈ LIM LONG** ស្ថិតនៅសង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ របស់លោកស្រី **ឡាំ សុភ័ក្រ** (ម្ចាស់ស្ថានីយ)។

**ប្រការ២**.-

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣**.-

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធររាជធានីភ្នំពេញ
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤**.-

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. កបំពង់ទទួលប្រេងត្រូវស្ថិតនៅចម្ងាយអប្បបរមា ៣ ម៉ែត្រពីរបងព្រំដីស្ថានីយ
២. កបំពង់ទទួលប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧ ម៉ែត្រពីអគារស្ថានីយ
៣. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ ម៉ែត្រពីរបងព្រំដីស្ថានីយ
៤. ពោងឧស្ម័នគួរមានចំណុះអតិបរមា ១០ តោន



៥ ៧

៥. ពោងឧស្ម័នត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧,៥ ម៉ែត្រពីអគារស្ថានីយ និង ៧,៥ ម៉ែត្រពីរបងព្រំដីស្ថានីយ

៦. ទូចាក់ឧស្ម័នត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រពីរបងព្រំដីស្ថានីយ

៧. ទូចាក់ប្រេងទៅទូចាក់ឧស្ម័នត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧ ម៉ែត្រ

៨. ត្រូវរៀបចំគន្លឹះអាសន្នរួមមួយ

៩. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក ។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្ដីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្ដាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្ដាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០៥០៧.រ.ម.អ.ប្រក.លក.....ចុះថ្ងៃទី....៤................ខែ..វិច្ឆិកា.....ឆ្នាំ២០២០.............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០៥០៧..រ.ម.អ.ប្រក.លក ចុះថ្ងៃទី....៤.........ខែ....វិច្ឆិកា........ឆ្នាំ២០២០...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពល រាជធានីភ្នំពេញ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.ពុធ..៤.រោច...ខែ..កត្តិក.....ឆ្នាំជូត.ទោស័កព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..៤.....ខែ.វិច្ឆិកា...ឆ្នាំ២០២០.

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០៥០៩ រ.ថ.អប្រក.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
## លេខ០៥០៩ រ.ថ.អប្រក.លអ.......ចុះថ្ងៃទី....០៤.....ខែ.វិច្ឆិកា....ឆ្នាំ ២០២០.

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១ សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញប្រកាសលេខ ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសារាចរលេខ ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០ របស់លោកស្រី **សូ ចាន់ដាវី**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈយីហោ **ភីធីធី** (ទួលពង្រ) ស្ថិតនៅភូមិធម្មត្រ័យ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ របស់លោកស្រី **សូ ចាន់ដាវី** (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមប្រកាសលេខ ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធី នៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមសារាចរលេខ ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពល។

**ប្រការ៥...**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពល ក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦...**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពល មុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាព នៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧...**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨...**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធិភាពខ្ពស់។

**ប្រការ៩...**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០...**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល រយៈពេល១ (មួយ) ខែយ៉ាងតិចមុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១...**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាពនៃលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ ០៥០៩ រ៉ែ:អប្រ.ក.ណអ ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០២០ របស់ក្រសួងរ៉ែនិងថាមពលនិងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះនិងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ០៤០៩.រ៩.អ.ប្រក.លអ ចុះថ្ងៃទី.........០៤..ខែ...វិច្ឆិកា........ឆ្នាំ២០២០...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.ពុធ..៤រោច.....ខែ..កត្តិក.....ឆ្នាំជូត..ទោស័ក.ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.....០៤.....ខែ..វិច្ឆិកា......ឆ្នាំ២០២០.

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ_សែម**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានីភ្នំពេញ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០៥១៥.រជ.អប្រក.ប្រក

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
**លេខ ០៥១៥.រជ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០២០**

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ របស់លោក **វន់ ប៊ុនថៃ**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ មានស្លាកយីហោ **តូតាល់ស្វាយអន្ទរ** ស្ថិតនៅភូមិស្វាយអន្ទរទី១ ឃុំស្វាយអន្ទរ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង របស់លោក **វន់ ប៊ុនថៃ (ម្ចាស់ស្ថានីយ)**។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមប្រកាសលេខ ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពលដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១.បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា២ម៉ែត្រ ពីរបងព្រំដីស្ថានីយ ហើយត្រូវមានជញ្ជាំងឬរបងការពារការប៉ះទង្គិចណាមួយ

២.ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្ដីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្ដល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាស នៅក្នុងសប្ដាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្ដាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែនិងថាមពល រយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០៥១៥ រ៉.វ.អគ្គប្រក.លអក.....ចុះថ្ងៃទី.....៤..............ខែ...វិច្ឆិកា......ឆ្នាំ២០២០..............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈ ពេល១២(ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ០៥១៥ រ៉.វ.អគ្គប្រក.លអក ចុះថ្ងៃទី.....៤.......ខែ...វិច្ឆិកា.........ឆ្នាំ២០២០....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។



៥៧

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយក នៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពល ខេត្តព្រៃវែង និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.ពុធ...៤.រោច...ខែ..កត្តិក.....ឆ្នាំជូត.ទោស័ក.ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...៤....ខែ.វិច្ឆិកា...ឆ្នាំ២០២០.

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**<u>កន្លែងទទួល:</u>**

-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-សាលាខេត្តព្រៃវែង
-ដូចប្រការ១៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខៈ ០៥១៦...រ៉ែ...ក.រ.ប្រក.ប៉ក

## ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
## លេខ ០៥១៦ រ៉ែ.ក.រ.ប្រក.ល.អ ចុះថ្ងៃទី...៨.......ខែ វិច្ឆិកា....ឆ្នាំ ២០២០

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយចម្រុះប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ របស់លោកស្រី ឡេង ស្រ៊ួយហៀង
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈមានស្លាកយីហោ **LHR** ថ្មគោល ស្ថិតនៅភូមិទំនាប ឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង របស់លោកស្រី ឡេង ស្រ៊ួយហៀង (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរខេត្ត
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានលំនៅដ្ឋានក្នុងទីធ្លាស្ថានីយ
២. ក្បាលដីស្ថានីយប្រេងឥន្ធនៈគួរមានប្រវែងអប្បបរមា ២៥ ម៉ែត្រ
៣. ពោងប្រេងឥន្ធនៈមួយដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ
៤. ពោងកប់ប្រេងឥន្ធនៈទៅលំនៅដ្ឋានត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រ
៥. អាងពោងកប់ប្រេងឥន្ធនៈទៅរបងព្រំដីស្ថានីយត្រូវស្ថិតនៅចម្ងាយអប្បបរមា ២,៥ ម៉ែត្រ



៤៧

៦. បំពង់ខ្យល់ទៅលំនៅដ្ឋានត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រ
៧. ត្រូវរៀបចំឱ្យមានកបំពង់ទទួលប្រេងឥន្ធនៈ
៨. ទូចាក់ប្រេងឥន្ធនៈទៅលំនៅដ្ឋានត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រ
៩. បំពង់ខ្យល់ទៅរបងព្រំដីស្ថានីយត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ ម៉ែត្រ
១០. ទូចាក់ប្រេងឥន្ធនៈទៅអគារការិយាល័យត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រ
១១. ទូចាក់ប្រេងឥន្ធនៈទៅរបងព្រំដីស្ថានីយត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រ
១២. ទុយោចាក់ប្រេងឥន្ធនៈមិនត្រូវមានប្រវែងលើសពី ៦ ម៉ែត្រ
១៣. ត្រូវគូសគំនូសសញ្ញាសម្រាប់ចំណតរថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ
១៤. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
១៥. ត្រូវបិទស្លាកសញ្ញាសុវត្ថិភាពឲ្យបានគ្រប់គ្រាន់
១៦. ត្រូវរៀបចំផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០៥១៦.រ.ថ.អ.បក.សអ.....ចុះថ្ងៃទី...៤.................ខែ..វិច្ឆិកា......ឆ្នាំ២០២០..............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០៥១៦.រ.ថ.អ.បក.សអ ចុះថ្ងៃទី....៤..........ខែ..វិច្ឆិកា.........ឆ្នាំ២០២០....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពល ខេត្តបាត់ដំបង និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.ពុធ..៤.រោច..ខែ..កត្តិក.....ឆ្នាំជូត.ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...៤...ខែ..វិច្ឆិកា...ឆ្នាំ២០២០.

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-សាលាខេត្តបាត់ដំបង
-ដូចប្រការ១៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០៤២០ រ៉ែ.អប្រេក.ប្រក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ

លេខ.០៤២០ រ៉ែ.អប្រេក.លអ.....ចុះថ្ងៃទី...១២......ខែ..វិច្ឆិកា.....ឆ្នាំ ២០២០.

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រេក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០ របស់លោក ព្រាប សាម៉េត
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្ដល់លិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ មានស្លាកយីហោ ដេប៉ូតេលា សាម៉េត ឡាយ ស្ថិតនៅភូមិក្រាំងក្អុក ឃុំកំពង់សឹង ស្រុកព្រះស្ដេចខេត្តព្រៃវែងរបស់លោក ព្រាប សាម៉េត (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមប្រកាសលេខ ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពលដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. ពោងកប់មួយត្រូវដាក់ប្រេងឥន្ធនៈ បានតែមួយប្រភេទប៉ុណ្ណោះ ហើយពោងប្រេងឥន្ធនៈនីមួយៗត្រូវមានចំណុះមិនឱ្យលើសពី៣០,០០០ (បីម៉ឺន) លីត្រ

២. កបំពង់ទទួលប្រេងត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧ម៉ែត្រ ពីអគារផ្សេងៗរបស់ស្ថានីយ

៣. ពោងឧស្ម័នឥន្ធនៈកប់ក្រោមដីឬដាក់លើដីមួយគួរមានចំណុះមិនលើសពី១០តោន

៤. ត្រូវបំពាក់គន្លឹះអាសន្ននៅតាមទូចាក់ឧស្ម័នឥន្ធនៈនីមួយៗ

៥. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែនិងថាមពល រយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ០៥២០១៥ រ.អធិក.ណ.អ............ចុះថ្ងៃទី.....១២............ខែ.....វិច្ឆិកា......ឆ្នាំ២០២១..............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។



៨៥

**ប្រការ១២.–.**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈ ពេល១២(ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០៥៧០.១៦:អ/ប.គ.លអ ចុះថ្ងៃទី...១៩.....ខែ...វិច្ឆិកា.........ឆ្នាំ២០២០....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.–.**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយក នៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពល ខេត្តព្រៃវែង និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍..១១កើត..ខែ..កត្តិក......ឆ្នាំជូត.ទោស័ក.ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.១៩.....ខែ..វិច្ឆិកា...ឆ្នាំ២០២០..

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តព្រៃវែង
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី